Advertisement

# របៀបយ៉ាងណាដើម្បីឲ្យគេរាប់សន្លឹកឆ្នោតរបស់លោកអ្នក។

# ការបោះឆ្នោតសហព័ន្ធ ថ្ងៃសៅរ៍ ទី២៤ ខែវិច្ឆិកា។

នៅថ្ងៃបោះឆ្នោត លោកអ្នកនឹងបានទទួលសន្លឹកឆ្នោតពីរសន្លឹក: សន្លឹកឆ្នោតពណ៌បៃតងគឺសំរាប់អ្នកតំណាងរាស្ត្រ ហើយនិងសន្លឹកឆ្នោតពណ៌សគឺសំរាប់ព្រឹទ្ធសភា។

## សន្លឹកឆ្នោតពណ៌បៃតង – សូមសរសេរដាក់លេខគ្រប់ទាំងប្រអប់នីមួយៗ។

ចំពោះសន្លឹកឆ្នោតពណ៌បៃតង លោកអ្នកត្រូវតែសរសេរដាក់លេខ **"1"** នៅក្នុងប្រអប់ក្បែរបេក្ខជនដែលជាជំរើសទី១របស់លោកអ្នក។ រួចមកសរសេរដាក់លេខ **"2"** នៅក្នុងប្រអប់ក្បែរជំរើសទី២របស់លោកអ្នកជាបន្តបន្ទាប់ រហូតទាល់តែលោកអ្នកសរសេរដាក់លេខបានគ្រប់ប្រអប់**នីមួយៗ**។ <u>សូមប្រុងប្រយ័ត្ន លោកអ្នកត្រូវតែសរសេរដាក់លេខគ្រប់ប្រអប់**នីមួយៗ** ដើម្បីឲ្យគេរាប់សន្លឹកឆ្នោតរបស់លោកអ្នកនៅក្នុងការបោះឆ្នោតសហព័ន្ធ។</u>

សូមកុំប្រើសញ្ញាក្បៀស ឬសញ្ញាជើងក្អែក ឬទុកប្រអប់ចោលដោយមិនបានសរសេរឲ្យសោះ បើពុំដូច្នោះទេនោះគេនឹងមិនរាប់សន្លឹកឆ្នោតរបស់លោកអ្នកឡើយ។




## សន្លឹកឆ្នោតពណ៌ស – របៀបបោះឆ្នោតពីរបែប។

ចំពោះសន្លឹកឆ្នោតពណ៌ស លោកអ្នកមានជំរើសបោះឆ្នោតពីរបែប។

### ពីលើខ្សែបន្ទាត់

លោកអ្នកគ្រាន់តែសរសេរដាក់លេខ **"1"** នៅក្នុងប្រអប់ពីលើខ្សែបន្ទាត់សំរាប់គណៈបក្ស ឬក្រុមណាមួយនៃជំរើសរបស់លោកអ្នកប៉ុណ្ណោះ។ តាមការធ្វើបែបនេះ លោកអ្នកធ្វើតាមបញ្ជីបោះឆ្នោតជាក្រុម (group voting ticket) ហើយអនុញ្ញាតឲ្យលំដាប់នៃចំណូលចិត្តរបស់លោកអ្នកត្រូវសំរេចដោយគណៈបក្ស ឬក្រុមរបស់លោកអ្នក។ ដើម្បីឲ្យបានដឹងច្រើនថែមទៀតអំពីបញ្ជីបោះឆ្នោតជាក្រុម សូមបើកមើលវ៉ិបសាយ www.aec.gov.au




ឬ

### ពីក្រោមខ្សែបន្ទាត់

លោកអ្នកអាចជ្រើសរើសបំពេញប្រអប់នីមួយនៅក្រោមខ្សែបន្ទាត់ ទៅតាមលំដាប់នៃចំណូលចិត្តរបស់លោកអ្នក។ លោកអ្នកត្រូវតែសរសេរដាក់លេខ **"1"** នៅក្នុងប្រអប់ក្បែរបេក្ខជនដែលជាជំរើសទី១របស់លោកអ្នក។ រួចមកសរសេរដាក់លេខ **"2"** នៅក្នុងប្រអប់ក្បែរជំរើសទី២របស់លោកអ្នកជាបន្តបន្ទាប់ រហូតទាល់តែលោកអ្នកសរសេរដាក់លេខបានគ្រប់ប្រអប់**នីមួយៗ**។




### ចុះប្រសិនបើខ្ញុំបំពេញខុស?

ប្រសិនបើលោកអ្នកបំពេញខុស កុំខ្វល់ព្រួយអ្វី: សូមគ្រាន់តែស្នើសុំសន្លឹកឆ្នោតថ្មីមួយទៀត ហើយចាប់ផ្តើមបំពេញម្តងទៀតប៉ុណ្ណោះ។

**ដើម្បីទទួលយកព័ត៌មានច្រើនថែមទៀតជាភាសាខ្មែរ សូមទូរស័ព្ទលេខ 1300 720 134 ឬ បើកមើលវិបសាយ www.aec.gov.au**

AEC
Australian Electoral Commission
*Your vote is a valuable thing*

ELECTION 2007

AEC7FORNP2/KHM

Authorised by Gail Urbanski, West Block, Queen Victoria Terrace, Parkes ACT.